រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ៨៤៤៧ ប្រក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រកាស
## ស្តីពី
## ការបង្កើត និងការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញា
## រដ្ឋបាលស្រុកអូររាំង ខេត្តមណ្ឌលគិរី

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារនិងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- យោងតាមសំណើរបស់រដ្ឋបាលខេត្តមណ្ឌលគិរី

## សម្រេច

**ប្រការ១ .–**

ត្រូវបានបង្កើតនិមិត្តសញ្ញារដ្ឋបាលស្រុកអូររាំង ខេត្តមណ្ឌលគិរី មានរូបរាង រូបភាព និងលក្ខណៈសម្គាល់ដូចខាងក្រោម៖

- និមិត្តសញ្ញាមានរាងមូលព័ទ្ធដោយខ្សែវណ្ឌពណ៌មាស បង្ហាញអំពីការគ្រប់គ្រងដែនដីរបស់រដ្ឋបាលស្រុក
- ជួរភ្នំមានពណ៌បៃតងនិងមានព្រៃឈើនិងខ្ពង់រាប តំណាងឱ្យធាតុដីដែលមានជីវជាតិដ៏ពិសិដ្ឋនៃភាពសម្បូរបែបរបស់ធម្មជាតិ មានព្រៃឈើ សត្វព្រៃគ្រប់ប្រភេទ និងជាទីកំណើតនៃមនុស្សជាតិ ដែលបម្រើឱ្យការរស់នៅរបស់ប្រជាជនទូទៅ និងការបង្កបង្កើនផលកសិកម្ម
- រូបបង្គោលទួប៊ីនខ្យល់ចំនួនបី មានពណ៌ស ជាតំណាងបច្ចេកវិទ្យាបង្កើតឡើងដោយមនុស្ស ដោយធាតុខ្យល់ និងធាតុភ្លើង ក្នុងដំណើរការដោយថាមពលខ្យល់បក់បង្កើតបានជាប្រភពថាមពលអគ្គិសនី សម្រាប់បម្រើឱ្យការរស់នៅរបស់ប្រជាជន និងជាប្រភពផ្គត់ផ្គង់យ៉ាងសំខាន់ក្នុងគ្រប់វិស័យរបស់ជាតិ
- រូបស្វាកន្ទុយស មានពណ៌ប្រផេះនិងពណ៌ស អង្គុយលើដើមធ្នង់ពណ៌ត្នោតកាន់ផ្លែកាហ្វេពណ៌ក្រហម តំណាងឱ្យភាពសម្បូរបែបនៃជីវៈចម្រុះ ព្រៃឈើ សត្វព្រៃក្នុងស្រុក។ សត្វស្វាកន្ទុយស ជាសត្វជិតផុតពូជលើភពផែនដីហើយមានវត្តមានក្នុងដែនអភិរក្សកែវសីមាក្នុងស្រុកអូររាំង សត្វស្វាប្រភេទនេះមានភាពល្បីល្បាញ ហើយបានទាក់ទាញយ៉ាងខ្លាំងដល់ភ្ញៀវទេសចរជាតិ និងអន្តរជាតិមកទស្សនាបែបអេកូទេសចរណ៍
- រូបផ្លែកាហ្វេមានពណ៌ក្រហម បង្ហាញអំពីសក្តានុពលវិស័យកសិកម្ម ដែលដំណាំកាហ្វេនេះជាប្រភពចំណូលដ៏សំខាន់សម្រាប់ប្រជាពលរដ្ឋដែលរស់នៅក្នុងស្រុកអូររាំង
- រូបផ្លូវកោងក្រាលកៅស៊ូ តំណាងឱ្យនៅក្នុងស្រុកអូររាំងមានផ្លូវច្រកទ្វារព្រំដែនអន្តរជាតិជាមួយប្រទេសជិតខាង ប្រជាពលរដ្ឋក្នុងស្រុកមានភាពងាយស្រួលធ្វើពាណិជ្ជកម្ម និងទំនាក់ទំនងការងារផ្សេងៗ
- អក្សរឈ្មោះ«រដ្ឋបាលស្រុកអូររាំង»មានពណ៌ស រំលេចក្នុងខ្សែបូពណ៌ក្រហមអមដោយខ្សែបូពណ៌ខៀវ ទ្រដោយផ្ការចនាក្បាច់ផ្កាចន្ទន៍ពណ៌មាសនៅក្នុងផ្ទៃពណ៌បៃតង តាមបែបសិល្បៈ និងវប្បធម៌ខ្មែរ
- ផ្ទៃពណ៌ផ្ទៃមេឃ បង្ហាញអំពីសន្តិភាព ភាពជឿជាក់ ភាពស្មោះត្រង់ និងភាពអំណត់។

**ប្រការ២ .–**

ត្រូវបានដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញារដ្ឋបាលស្រុកអូររាំង ខេត្តមណ្ឌលគិរី ដូចមានក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

និមិត្តសញ្ញារដ្ឋបាលស្រុកអូររាំង ខេត្តមណ្ឌលគិរី ត្រូវប្រើប្រាស់ដូចខាងក្រោម៖

- ដាក់នៅកន្លែងធ្វើការងារនៅរដ្ឋបាលស្រុកអូររាំង

- ប្រើប្រាស់នៅលើលិខិត ស្រោមសំបុត្រ ឯកសណ្ឋាន និងឯកសារផ្លូវការពាក់ព័ន្ធរបស់រដ្ឋបាលស្រុកអូររាំង
- ប្រើប្រាស់ក្នុងពិធីនានា និងប្រើប្រាស់ក្នុងកិច្ចការជាផ្លូវការផ្សេងៗតាមការចាំបាច់។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានមនុស្ស ប្រធានអង្គភាពផ្សេងទៀតចំណុះក្រសួងមហាផ្ទៃ ប្រធានក្រុមប្រឹក្សាខេត្តមណ្ឌលគិរី អភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី ប្រធានក្រុមប្រឹក្សាស្រុកអូររាំង និងអភិបាលនៃគណៈអភិបាលស្រុកអូររាំង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ...សុក្រ...៣កើត...ខែ...ទុតិយាសាឍ...ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...១៧...ខែ...កក្កដា...ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋាន គ.ជ.អ.ប.
- រដ្ឋបាលខេត្តមណ្ឌលគិរី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ៨៤៤៧..ប្រក ចុះថ្ងៃ.សុក្រ....៣កើត...ខែបឋមាសាឍ...ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី១៧..ខែ.កក្កដា...ឆ្នាំ២០២៦ ស្តីពីការបង្កើត និងការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញារដ្ឋបាលស្រុកអូររាំង ខេត្តមណ្ឌលគិរី។

## និមិត្តសញ្ញារដ្ឋបាលស្រុកអូររាំង